# ការខូបត្ថម្ភតាមមាគ៌ារបស់ព្រះអម្ចាស់

*ដោយប្រធាន ឌៀថើរ អែហ្វ អុចដុហ្វ*
*ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ*

កាលពីហុកសិបប្រាំឆ្នាំមុន មិនយូរប៉ុន្មានបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ ខ្ញុំមានបទពិសោធន៍ផ្ទាល់ខ្លួនមួយអំពីពរជ័យនៃកម្មវិធីសុខុមាលភាពរបស់សាសនាចក្រ ។ ទោះជាខ្ញុំនៅក្មេង តែខ្ញុំនៅចាំរសជាតិផ្អែមនៃផ្លែ ភិចកំប៉ុង ជាមួយនឹងបបរស្រូវសាឡី ហើយជាពិសេស ក្លិនខោអាវបរិច្ចាគដែលសមាជិកសាសនាចក្រនៅសហរដ្ឋបានបញ្ជូនទៅកាន់ពួកបរិសុទ្ធអាល្លឺម៉ង់ក្រោយពេលសង្គ្រាម ។

ខ្ញុំនឹងគោរពដល់ទង្វើនៃក្ដីស្រឡាញ់ និង សណ្ដានចិត្តល្អទាំងនេះជារៀងរហូតដល់ អ្នកក្នុងចំណោមពួកយើង ដែលបានមានតម្រូវការយ៉ាងខ្លាំង ។

បទពិសោធន៍ផ្ទាល់ខ្លួន និង បុណ្យខួបលើកទី 75 នៃផែនការសុខុមាលភាពដ៏បំផុសគំនិតនេះ បានផ្ដល់ហេតុឲ្យខ្ញុំពិចារណាឡើងវិញ ពីគោលការណ៍គ្រឹះនៃការយកចិត្តទុកដាក់ចំពោះជនទុរគត និង ជនទ័លក្រ និងការក្លាយជាមនុស្សខ្លួនទីពឹងខ្លួន និង ការបម្រើដល់បងប្អូនរបស់យើង ។

## នៅត្រង់ឫសគល់នៃសេចក្ដីជំនឿរបស់យើង

ពេលខ្លះ យើងគិតថាសុខុមាលភាពជាប្រធានបទដំណឹងល្អសាមញ្ញមួយទៀត --- ជាមែកធាងមួយនៃមែកធាងជាច្រើននៅលើដើមដំណឹងល្អ ។ ប៉ុន្តែខ្ញុំជឿថា ផែនការរបស់ព្រះអម្ចាស់ ការតាំងចិត្តរបស់យើងចំពោះគោលការណ៍សុខុមាលភាព គួរតែមាននៅគ្រប់ឫសគល់នៃសេចក្ដីជំនឿ និងការលះបង់របស់យើងចំពោះទ្រង់ ។

ចាប់តាំងពីដំបូងឡើយ ព្រះវរបិតាសួគ៌របស់យើង មានបន្ទូលយ៉ាងច្បាស់អំពីប្រធានបទនេះ ៖ រួមមានទាំងការអង្វរថា ៖ « បើសិនជាអ្នកស្រឡាញ់យើង . . . ចូរនឹកដល់មនុស្សទាល់ក្រ ហើយថ្វាយទ្រព្យសម្បត្តិទាំងឡាយរបស់ខ្លួន សម្រាប់គាំទ្រពួកគេ » [1] ក៏ដូចជាការបញ្ជាចំៗថា ៖ « ចូរនឹកចាំក្នុងគ្រប់ការណ៍ទាំងអស់ ពីមនុស្សទាល់ក្រ និង មនុស្សកំសត់ទុគត៌ មនុស្សឈឺ និង មនុស្សមានទុក្ខ ត្បិតអ្នកណាដែលមិនធ្វើការទាំងនេះទេ អ្នកនោះឈ្មោះថាមិនមែនជាសិស្សរបស់យើងឡើយ » [2] និងជាការព្រមានដោយសង្កត់ធ្ងន់ និង ដោយអំណាចថា « បើសិនជាមានមនុស្សណាមួយយកពីរបស់បរិបូរដែលយើងបានបង្កើតមក ហើយពុំចែកចំណែករបស់ខ្លួនតាមក្រិត្យវិន័យ នៃដំណឹងល្អរបស់យើង ដល់មនុស្សទាល់ក្រ និងមនុស្សកំសត់ទុគត៌ទេ អ្នកនោះនឹងសម្លឹងភ្នែកឡើងនៅក្នុងស្ថាននរក ជាមួយមនុស្សទុច្ចរិតនៅក្នុងការរងទុក្ខវេទនា » ។ [3]

## ខាងសាច់ឈាម និង ខាងវិញ្ញាណ ត្រូវបានចងភ្ជាប់ជាមួយគ្នា

បទបញ្ញត្តិធំពីរ --- ឲ្យស្រឡាញ់ព្រះ និង អ្នកជិតខាងរបស់យើង --- ជាការវេញចូលគ្នាទាំងខាងសាច់ឈាម និង ខាងវិញ្ញាណ ។ វាសំខាន់ណាស់ដើម្បីកំណត់ចំណាំថា បញ្ញត្តិទាំងពីរនេះ ត្រូវបានហៅថា «ធំ» ដោយសារបណ្ដាក្រិតវិន័យដទៃទៀតទាំងអស់ សំរេចនៅបទបញ្ញត្តទាំងពីរប្រការនេះឯង ។ [4] ជាពាក្យម្យ៉ាងទៀត អាទិភាពផ្ទាល់ខ្លួន គ្រួសារ និង សាសនាចក្រ ត្រូវតែចាប់ផ្ដើមជាមួយនឹងបទបញ្ញត្តិទាំងពីរនេះ ។ គោលដៅ និង សកម្មភាពដទៃទៀតទាំងអស់ គួរតែចេញមកពីប្រភពនៃបទបញ្ញត្តិធំពីរនេះ--- ចេញមកពីក្ដីស្រឡាញ់របស់យើងចំពោះព្រះ និង អ្នកជិតខាងរបស់យើង ។

ខាងសាច់ឈាម និង ខាងវិញ្ញាណ ពុំអាចបំបែកចេញពីគ្នាបានឡើយ គឺដូចជាមុខកាក់ទាំងសង្ខាងដូច្នោះដែរ ។

អង្គបង្កើតជីវិតទាំងអស់ បានប្រកាសថា « អស់ទាំងរបស់របរគ្រប់យ៉ាង គឺជាវិញ្ញាណចំពោះយើង ហើយគ្មានពេលណាមួយ ដែលយើងបានប្រទានពរដល់អ្នកនូវក្រិត្យវិន័យណាមួយដែលត្រូវជារបស់ខាងសាច់ឈាមនោះឡើយ » ។ [5] នេះមានន័យចំពោះខ្ញុំថា « ជីវិតខាងវិញ្ញាណ គឺជា *ជីវិត*សំខាន់ជាងគេបំផុត ។ វាពុំគ្រាន់តែជាអ្វីត្រូវស្គាល់ និង សិក្សានោះទេ គឺដើម្បីឲ្យរស់នៅតាម » ។ [6]

ជាអកុសល មានមនុស្សមួយចំនួនមើលរំលង « ខាងសាច់ឈាម » ដោយសារពួកគេគិតថា វាពុំសូវសំខាន់ ។ ពួកគេសន្សំទុកខាងវិញ្ញាណ តែកាត់បន្ថយខាងសាច់ឈាម ។ ខណៈពេលដែលយើងគិតផ្ដោតឆ្ពោះទៅរកស្ថានសួគ៌ បើសិនជាសកម្មភាពរបស់យើងពុំផ្ដោតទៅរកបងប្អូនរបស់យើងនោះ យើងភ្លេចពីសារៈសំខាន់នៃសាសនា » ។

ឧទាហរណ៍ ហេណុក សង់សង្គមស៊ីយ៉ូនមួយឡើង តាមរយៈដំណើរការខាងវិញ្ញាណ ក្នុងការបង្កើតមនុស្សឲ្យមានចិត្ត និង គំនិតតែមួយ *ហើយនឹង* កិច្ចការខាងសាច់ឈាម ដើម្បីប្រាកដថា គ្មានមនុស្សទាល់ក្រក្នុងចំណោមពួកគេ ។ [7]

ជានិច្ចកាល យើងអាចមើលទៅគ្រូបង្រៀន និង គំរូដ៏ឥតខ្ចោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ ទុកសម្រាប់ជាគំរូមួយ ។ ដូចជាប្រធាន ជេ រ៉ូប៊ឺន ក្លាក បានបង្រៀនថា « នៅពេលព្រះអង្គសង្គ្រោះ យាងមកលើផែនដី ទ្រង់មានបេសកកម្មធំពីរ ទីមួយ គឺដើម្បីបំពេញតួនាទីជាព្រះមែស៊ី ដង្វាយធួនសម្រាប់ការធ្លាក់ និង បំពេញតាមក្រិត្យវិន័យ ហើយមួយទៀត គឺធ្វើការដែលទ្រង់បានធ្វើនៅក្នុងចំណោមបងប្អូសប្រុសស្រីរបស់ទ្រង់ ខាងសាច់ឈាម ដើម្បីទ្រង់បានសម្រាលទុក្ខរបស់ពួកគេ » ។ [8]

ស្រដៀងគ្នានេះដែរ ការរីកចម្រើនខាងវិញ្ញាណរបស់យើង គឺចងភ្ជាប់គ្នាពុំអាចបំបែកបាន ជាមួយនឹងការបម្រើខាងសាច់ឈាម ដែលយើងផ្ដល់ដល់អ្នកដទៃ ។

វាបំពេញឲ្យគ្នាទៅវិញទៅមក ។ បើមានមួយអត់មួយ គឺជាការក្លែងបន្លំផែនការនៃសុភមង្គលរបស់ព្រះហើយ ។

**មាគ៌ារបស់ព្រះអម្ចាស់**

មានមនុស្ស និង អង្គការល្អៗជាច្រើននៅក្នុងពិភពលោក ដែលកំពុងតែព្យាយាម ដើម្បីបំពេញតាមតម្រូវការបន្ទាន់មនុស្សទាល់ក្រ និង ទុរគតិនៅគ្រប់ទីកន្លែង ។ យើងមានអំណរគុណចំពោះរឿងនេះ ប៉ុន្តែតាមមាគ៌ារបស់ព្រះអម្ចាស់ក្នុងការមើលថែដល់មនុស្សទុរគតិ គឺខុសពីរបៀបរបស់លោកីយ ។ ព្រះអម្ចាស់បានមានបន្ទូលថា « ការនេះត្រូវបានសម្រេចតាមមាគ៌ារបស់យើង » ។ [9] ទ្រង់ពុំមែនចាប់អារម្មណ៍តែចំពោះតម្រូវការភ្លាមៗរបស់យើងប៉ុណ្ណោះទេ តែទ្រង់ខ្វល់ព្រះទ័យអំពីការរីកចម្រើនដ៏អស់កល្បជានិច្ចរបស់យើង ។ ដោយមូលហេតុនេះ មាគ៌ារបស់ព្រះអម្ចាស់ តែងតែមានរួមបញ្ចូលនូវ ភាពខ្លួនទីពឹងខ្លួន និង ការបម្រើចំពោះអ្នកជិតខាង ជាការបន្ថែមទៅលើការមើលថែដល់មនុស្សទាល់ក្រ ។

ក្នុងឆ្នាំ 1941 ទន្លេ ហ្គីឡា បានជន់លិចជ្រលង ឌូកាន នៅរដ្ឋ អារីហ្សូណា ។ ប្រធានស្តេករ៍យែក្មេង ឈ្មោះស្ពែនស៊ើរ ដបុលយូ឴ យឹមបឹល បានជួបជាមួយនឹងទីប្រឹក្សាទាំងឡាយរបស់លោកប៉ាន់ស្មានពីការខូចខាត ហើយបានបញ្ជូនតេឡេក្រាម ទៅកាន់ទីក្រុងសលត៍ លេក សុំថវិកាយ៉ាងច្រើន ។

ជំនួសឲ្យការបញ្ជូនថវិការ ប្រធាន ហ៊ីប៊ើរ ចេ ក្រាន្ត បានបញ្ជូនបុរសបីរូបគឺ ៖ ហៃនរី ឌី ម៉ូឡឺ, ម៉ារ៉ុន ជី រ៉មនី និងហារ៉ូល ប៊ី លី ឲ្យទៅ ។ ពួកគាត់បានទៅជួបប្រធាន យឹមបឹល ហើយបានបង្រៀនមេរៀនសំខាន់មួយដល់គាត់ ៖ ពួកគាត់បានមានប្រសាសន៍ថា « នេះពុំមែនជាកម្មវិធី ‹ផ្ដល់ឲ្យខ្ញុំ› ទេ ។ « វាគឺជាកម្មវិធី ‹ការជួយខ្លួនឯង› » ។

ជាច្រើនឆ្នាំក្រោយមក ប្រធាន យឹមបឹល បានមានប្រសាសន៍ថា ៖ « ខ្ញុំគិតថា វានឹងងាយស្រួល សម្រាប់បងប្អូនប្រុសផ្ញើរ [ ប្រាក់] ឲ្យយើង ហើយវានឹងពុំពិបាកខ្លាំងដើម្បីអង្គុយនៅក្នុងការិយាល័យរបស់ខ្ញុំ ហើយបែងចែកវា ប៉ុន្តែមានសេចក្ដីល្អកើតឡើងយ៉ាងច្រើនដល់យើង នៅពេលយើងមាន [ សមាជិករបស់យើង ] រាប់ពាន់នាក់ ទៅ ឌូកាន សង់រនាំង និងអូសចំបើង លើកដីទប់ ហើយធ្វើអ្វីគ្រប់យ៉ាងដែលចាំបាច់ត្រូវធ្វើ ។ នោះគឺជាការជួយខ្លួនឯង » ។ [10]

តាមរយៈការធ្វើតាមមាគ៌ារបស់ព្រះអម្ចាស់ នោះសមាជិកក្នុងស្តេករបស់ប្រធាន យឹមបឹល ពុំគ្រាន់តែបំពេញតាមតម្រូវការភ្លាមៗរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏បានអភិវឌ្ឍភាពខ្លួនទីពឹងខ្លួន សម្រាលការរងទុក្ខ ហើយចម្រើនសេចក្ដីស្រឡាញ់ និង សាមគ្គីភាព នៅពេលពួកគេបម្រើគ្នាទៅវិញទៅមក ។

**យើងទាំងអស់គ្នាត្រូវបានហៅឲ្យចូលរួម**

នៅខណៈពេលនេះ មានសមាជិកសាសនាចក្រជាច្រើន ដែលកំពុងតែរងទុក្ខ ។ ពួកគេកំពុងតែស្រេកឃ្លាន ខ្វះខាតធនធានហិរញ្ញវត្ថុ និង ពុះពារជាមួយនឹងរឿងឈឺចាប់ខាងរូបកាយ សតិអារម្មណ៍ និង ខាងវិញ្ញាណគ្រប់បែបយ៉ាង ។ ពួកគេអធិស្ឋានដោយអស់ពីកម្លាំងចិត្តរបស់ពួកគេ សុំជំនួយ សុំការធូរស្បើយ ។

ឱ បងប្អូនប្រុស សូមកុំគិតថា នេះគឺជាការទទួលខុសត្រូវរបស់អ្នកផ្សេង ។ វាគឺជាការទទួលខុសត្រូវរបស់ខ្ញុំ និង អ្នក ។ យើងទាំងអស់គ្នាត្រូវបានហៅឲ្យធ្វើការនេះ ។ « ទាំងអស់គ្នា » មានន័យថាគឺ *ទាំងអស់គ្នា* --- គ្រប់អ្នកកាន់បព្វជិតភាពអើរ៉ុន និង មិលគីស្សាដែក អ្នកមាន អ្នកក្រ នៅគ្រប់ជាតិសាសន៍ ។ នៅក្នុងផែនការរបស់ព្រះអម្ចាស់ មានអ្វីមួយសម្រាប់មនុស្សគ្រប់រូប អាចបរិច្ចាគ ។ [11]

មេរៀនដែលយើងរៀនពីមួយជំនាន់ទៅមួយជំនាន់ គឺថា អ្នកមាន អ្នកក្រ *ទាំងអស់គ្នា* ស្ថិតនៅក្រោមកាតព្វកិច្ចពិសិដ្ឋដើម្បីជួយដល់អ្នកជិតខាងរបស់ពួកគេដូចគ្នា ។ វានឹងចាំបាច់ឲ្យយើងទាំងអស់គ្នា ធ្វើការជាមួយគ្នា ដើម្បីអនុវត្តគោលការណ៍សុខុមាលភាព និង ភាពខ្លួនទីពឹងខ្លួនដោយជោគជ័យ ។

ជាញឹកញាប់ យើងកត់សំគាល់ឃើញមានតម្រូវការនៅជុំវិញយើង ដោយសង្ឃឹមថា មាននរណាម្នាក់មកពីចម្ងាយ មកបំពេញតម្រូវការទាំងនោះ ។ ប្រហែលជាយើងរង់ចាំឲ្យអ្នកជំនាញ ដែលមានចំណេះដឹងខាងឯកទេស ដោះស្រាយបញ្ហាជាក់លាក់មក ។ នៅពេលយើងធ្វើដូច្នេះ យើងបដិសេធការបម្រើរបស់អ្នកជិតខាងយើង ដែលអាចផ្ដល់ដល់យើង ហើយយើងបដិសេធខ្លួនយើងពីឱកាសដើម្បីបម្រើ ។ វាគ្មានទាស់អ្វីនឹងអ្នកជំនាញទេ តាមពិតគឺ ៖ គ្មានអ្នកជំនាញគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហាទាំងអស់ទេ ។ ផ្ទុយទៅវិញ ព្រះអម្ចាស់បានផ្ដល់អ្នកកាន់បព្វជិតភាព និង អង្គការបព្វជិតភាពសម្រាប់យើងនៅទូទាំងពិភពលោក ។ ហើយព្រមជាមួយគ្នានោះ ទ្រង់ក៏បានផ្ដល់សមាគមសង្គ្រោះ ។ យើងជាអ្នកកាន់បព្វជិតភាពដឹងថា កិច្ចការសុខុមាលភាពពុំអាចទទួលជោគជ័យទេ បើពុំប្រើអំណោយទាន និងទេពកោសល្យដ៏អស្ចារ្យរបស់បងប្អូនស្ត្រីនោះ ។

មាគ៌ារបស់ព្រះអម្ចាស់ ពុំមែនអង្គុយនៅមាត់ច្រាំង រង់ចាំឲ្យទឹកស្រកមុនពេលយើងឆ្លងទៅនោះទេ ។ យើងត្រូវរួបរួមគ្នា លាត់ដៃអាវ ចេញទៅធ្វើការសង់ស្ពាន ឬ ទូក ដើម្បីឆ្លងទឹកនៃឧបសគ្គរបស់យើង ។ បុរសនៃស៊ីយ៉ូន អ្នកកាន់បព្វជិតភាព គឺជាអ្នកដែលអាចដឹកនាំ និងនាំការសម្រាកទុក្ខដល់ពួកបរិសុទ្ធ ដោយការអនុវត្តន៍គោលការណ៍បំផុសគំនិតនៃកម្មវិធីសុខុមាលភាព! វាគឺ ជាបេសកកម្មរបស់អ្នកដើម្បីបើកភ្នែករបស់អ្នក ប្រើបព្វជិតភាពរបស់អ្នក ហើយទៅធ្វើការតាមមាគ៌ារបស់ព្រះអម្ចាស់ ។

**អង្គការដ៏ធំបំផុតនៅលើផែនដី**

អំឡុងពេលវិបត្តិសេដ្ឋកិច្ចដ៏ធំ ហារ៉ូល ប៊ី លី ត្រូវបានបងប្អូនប្រុសសុំឲ្យរកចម្លើយចំពោះភាពក្រីក្រសង្កត់សង្កិន ភាពសោកសៅ និង ការស្រេកឃ្លាន ដែលបានសាយភាយយ៉ាងខ្លាំងទូទាំងពិភពលោកនាគ្រានោះ ។ គាត់បានពុះពារក្នុងការរកដំណោះស្រាយ ហើយបាននាំបញ្ហានេះទៅកាន់ព្រះអម្ចាស់ រួចទូលសួរថា « តើអង្គការប្រភេទណា ដែលពួកយើងត្រូវការឲ្យ ...ធ្វើការនេះ ? »

ហើយ « ព្រះអម្ចាស់បានមានបន្ទូល [មកគាត់] ថា ៖ ‹មើលចុះកូនប្រុស ។ អ្នកពុំត្រូវការអង្គការណាផ្សេងទៀតឡើយ ។ យើងបានប្រទានអង្គការដ៏មហិមាបំផុត ឲ្យមាននៅលើផែនដីដល់អ្នកហើយ ។ គ្មានអង្គការណាធំជាងអង្គការបព្វជិតភាពឡើយ ។ អ្វីទាំងអស់ដែលអ្នកចាំបាច់ត្រូវធ្វើក្នុងលោកីយនេះ គឺចាត់ឲ្យអ្នកកាន់បព្វជិតភាពចេញទៅធ្វើការចុះ ។ គឺ តែប៉ុណ្ណឹង› » ។ [12]

នោះជាចំណុចចាប់ផ្ដើមនៅក្នុងគ្រារបស់យើងផងដែរ ។ យើងមានអង្គការរបស់ព្រះអម្ចាស់រួចជាស្រេចហើយ ។ ឧបសគ្គរបស់យើងគឺត្រូវកំណត់របៀបដើម្បីប្រើវា ។

កន្លែងដើម្បីចាប់ផ្ដើមគឺត្រូវធ្វើឲ្យខ្លួនយើងស្គាល់នូវអ្វីដែលព្រះអម្ចាស់ បានបើកសម្ដែងរួចហើយនោះ ។ យើងពុំគួរស្មានថា យើងដឹងហើយនោះទេ ។ យើងចាំបាច់ត្រូវចូលទៅកាន់ប្រធានបទនោះដោយភាពរាបទាបឲ្យដូចជាកូនក្មេង ។ គ្រប់ជំនាន់ត្រូវរៀនគោលលទ្ធិថ្មី ដែលជាគ្រឹះនៃមាគ៌ារបស់ព្រះអម្ចាស់ ក្នុងការមើលថែដល់ជនទុគ៌ត ។ ដូចជាព្យាការីជាច្រើនបានបង្រៀនដល់យើងអស់ជាច្រើនឆ្នាំកន្លងទៅ គោលការណ៍សុខុមាលភាពនៃសាសនាចក្រ ពុំមែនគ្រាន់តែជាយោបល់ល្អនោះទេ តែវាត្រូវបានបើកសម្ដែងសេចក្ដីពិតមកពីព្រះ--- វាគឺជាមាគ៌ារបស់ទ្រង់ក្នុងការជួយដល់ជនទុគ៌ត ។

បងប្អូនប្រុស សូមសិក្សាគោលការណ៍ និង គោលលទ្ធិដែលបានបើក សម្តែងជាមុនសិន ។ សូមអានក្បួនខ្នាតស្តីអំពីសុខុមាលភាពសាសនាចក្រ 13 ឆ្លៀតយកប្រយោជន៍ពីគេហទំព័រអ៊ិនធើរណិត « providentliving.org » អានអត្ថបទផែនការសុខុមាលភាពរបស់សាសនាចក្រក្នុងទស្សនាវដ្ដី *លីអាហូណា /Ensign* ខែមិថុនា ឆ្នាំ 2011 សារឡើងវិញ ។ ស្រាវជ្រាវអំពីការផ្គត់ផ្គង់តាមមាគ៌ារបស់ព្រះអម្ចាស់ សម្រាប់ពួកបរិសុទ្ធរបស់ទ្រង់ ។ ចូររៀនអំពីរបៀបដែលគោលការណ៍នៃការថែទាំជនទុរគតិ បម្រើដល់អ្នកជិតខាង និងភាពខ្លួនទីពឹងខ្លួនបំពេញឲ្យគ្នាទៅវិញទៅមក ។ មាគ៌ារបស់ព្រះអម្ចាស់អំពីភាពខ្លួនទីពឹងខ្លួន ជាប់ទាក់ទងនឹងវិធីធ្វើឲ្យមានលំនឹងនៅក្នុងទិដ្ឋភាពនៃជីវិតជាច្រើន រួមមាន ការអប់រំ សុខ-ភាព ការងារ ហិរញ្ញវត្ថុគ្រួសារ និង កម្លាំងខាងវិញ្ញាណ ។ អ្នករៀនស្គាល់កម្មវិធីសុខុមាលភាពសម័យទំនើបរបស់សាសនាចក្រ ។ [14] នៅពេល អ្នកបានសិក្សាគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃសុខុមាលភាព សាសនាចក្រ ចូរព្យាយាមអនុវត្តនូវអ្វីដែលអ្នកបានរៀនចំពោះតម្រូវការរបស់អ្នកទាំងឡាយ ដែលស្ថិតនៅក្នុងការទទួលខុសត្រូវរបស់អ្នក ។ នោះមានន័យសំខាន់ថា អ្នកនឹងរិះគិតដោយខ្លួនអ្នក ។ គ្រប់ក្រុមគ្រួសារ មានក្រុមជំនុំ គ្រប់តំបន់ក្នុងពិភពលោកមានភាពខុសគ្នា ។ គ្មានចម្លើយតែមួយឆ្លើយគ្រប់សុខុមាលភាពក្នុងសាសនាចក្រនោះទេ ។

អ្នកនឹងត្រូវធ្វើផែនការដែលត្រូវតាមគោលលទ្ធិរបស់ព្រះអម្ចាស់ ហើយត្រូវនឹងស្ថានភាពក្នុងតំបន់ភូមិសាស្ត្ររបស់អ្នក ។ ដើម្បីអនុវត្តគោលការណ៍សុខុមាលភាពដ៏ទេវភាពនេះ អ្នកពុំចាំបាច់មើលទៅទីក្រុងសលត៍លេកជានិច្ចនោះទេ ។ ផ្ទុយទៅវិញ អ្នកចាំបាច់ត្រូវមើលនៅក្នុងក្បួនខ្នាត ក្នុងចិត្តរបស់អ្នក និង ទៅស្ថានសួគ៌ ។ ចូរទុកចិត្តលើការបំផុសគំនិតរបស់ព្រះអម្ចាស់ ហើយធ្វើតាមមាគ៌ារបស់ទ្រង់ ។

ជាយថាហេតុ អ្នកត្រូវធ្វើនៅក្នុងតំបន់របស់អ្នកនូវគោលការណ៍ណាដែលព្រះគ្រីស្ទ បានធ្វើនៅគ្រប់គ្រាកាន់កាប់ត្រួតត្រា ៖ ប្រឹក្សាជាមួយគ្នា ប្រើគ្រប់ធនធានដែលមាន ស្វែងរកការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ទូលព្រះអម្ចាស់សុំការបញ្ជាក់ពីទ្រង់ បន្ទាប់មក លាត់ដៃអាវរបស់អ្នក ហើយចេញទៅធ្វើការ ។

ខ្ញុំសូមសន្យានឹងអ្នក បើសិនជាអ្នកនឹងធ្វើតាមគំរូនេះ អ្នកនឹងទទួលការណែនាំជាក់លាក់ យ៉ាងលំអិតអំពី *នរណា អ្វី នៅពេលណា* និង *កន្លែងណា* ដើម្បីឧបត្ថមតាមមាគ៌ារបស់ព្រះអម្ចាស់ ។

**ពរជ័យនៃការឧបត្ថមតាមមាគ៌ារបស់ព្រះអម្ចាស់**

ការសន្យាដែលព្យាករ និង ពរជ័យនៃសុខុមាលភាពសាសនាចក្រ នៃការឧបត្ថមតាមមាគ៌ារបស់ព្រះអម្ចាស់ គឺជារឿងដ៏សំខាន់ និង អស្ចារ្យបំផុត ដែលព្រះអម្ចាស់ បានប្រទានមកដល់កូនចៅរបស់ទ្រង់ថា ៖ « បើឯងផ្តល់សេចក្តីសប្បុរសដល់មនុស្សស្រេកឃ្លាន ទាំងចំអែតចិត្តនៃអ្នកដែលមានទុក្ខវេទនា នោះពន្លឺរបស់ឯងនឹងបានភ្លឺ ដូចជាវេលាថ្ងៃត្រង់ ៖ ហើយព្រះអម្ចាស់ទ្រង់នឹងនាំផ្លូវឯងជានិច្ច » ។ [15]

ទោះជាយើងមាន ឬ ក្រ មិនថាយើងនៅកន្លែងណាទេ យើងទាំងអស់គ្នាត្រូវការគ្នាទៅវិញទៅមក ត្បិតនៅក្នុងការលះបង់ពេលវេលា ទេពកោសល្យ និង ធនធានរបស់យើង នោះវិញ្ញាណរបស់យើងនឹងមានភាពចាស់ទុំ ហើយបានបរិសុទ្ធ ។

កិច្ចការនៃការឧបត្ថមតាមមាគ៌ារបស់ព្រះអម្ចាស់នេះ ពុំមែនគ្រាន់តែជា ចំនុចមួយសាមញ្ញនៅក្នុងបញ្ជីនៃកម្មវិធីរបស់សាសនាចក្រទេ ។ ពុំអាចមិនគិត ឬដាក់វាដាច់ដោយឡែកបានឡើយ ។ វាគឺជាចំណុចសំខាន់ចំពោះគោលលទ្ធិរបស់យើង វាជាចំនុចសំខាន់នៃសាសនាយើង ។ ឱ បងប្អូនប្រុស វាគឺជាឯកសិទ្ធិដ៏មហិមា និង ពិសេសរបស់យើង ក្នុងនាមជាពួកអ្នកកាន់បព្វជិតភាព ដើម្បីប្រើបព្វជិតភាព ។ យើងមិនត្រូវបង្វែរដួងចិត្ត ឬ ងាកចេញពីការប្រែក្លាយជាមនុស្សកាន់តែមានភាពខ្លួនទីពឹងខ្លួន កាន់តែមើលថែដល់ជនទុរគតិ និង កាន់តែផ្តល់ការបម្រើដោយក្តីមេត្តានោះឡើយ ។

កិច្ចការខាងសាច់ឈាម គឺមានទំនាក់ទំនងយ៉ាងជិតស្និតទៅនឹងកិច្ចការខាងវិញ្ញាណ ។ ព្រះបានប្រទានដល់យើងនូវបទពិសោធន៍នៃជីវិតរមែងស្លាប់ និង ឧបសគ្គខាងសាច់ឈាមនេះ ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយវា ដូចជាទីពិសោធន៍ ដែលយើងអាចរីកចម្រើន ឲ្យទៅជាមនុស្ស ដែលព្រះវរបិតាសួគ៌សព្វព្រះទ័យចង់ឲ្យយើងប្រែក្លាយ ។ សូមឲ្យយើងយល់ពីកាតព្វកិច្ច និង ពរជ័យដ៏មហិមា ដែលកើតមាន មកពីការធ្វើតាម និង ការឧបត្ថមតាមមាគ៌ារបស់ព្រះអម្ចាស់ នៅក្នុងការអធិស្ឋានរបស់ខ្ញុំ នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. គោលលទ្ធិ និង សេចក្តីសញ្ញា 42:29—30 ។
2. គោលលទ្ធិ និង សេចក្តីសញ្ញា 52:40 ។

3. គោលលទ្ធិ និង សេចក្ដីសញ្ញា 104:18 ។

4. សូមមើល ម៉ាថាយ 22:36—40 ។

5. គោលលទ្ធិ និង សេចក្ដីសញ្ញា 29:34 ។

6. ថូម៉ាស មើរតុន, *Thoughts in Solitude* (ឆ្នាំ 1956), 37 ។

7. សូមមើ ម៉ូសេ 7:18 ។

8. J. Reuben Clark Jr.ក្នុង Conference Report ខែ មេសា ឆ្នាំ 1937 ទំព័រ 22 ។

9. គោលលទ្ធិ និង សេចក្ដីសញ្ញា 104:16; សូមមើលខ 15 ផងដែរ ។

10. ស្ពែនស៊ើរ ដបុលយូ឵ ឃឹមបិល ក្នុង Conference Reportខែ មេសា ឆ្នាំ 1974 ទំព័រ 183, 184 ។

11. សូមមើល ម៉ូសាយ 4:26; 18:27 ។

12. ហារ៉ូល ប៊ី លី ប្រសាសន៍ផ្ដល់ឲ្យនៅការប្រជុំសុខុមាលភាពខាងកសិកម្ម ថ្ងៃទី 3 ខែ តុលា ឆ្នាំ 1970 ទំព័រ 20 ។

13. សូមមើល *ក្បួនខ្នាតភាគ 1 ៖ ប្រធានស្តេក និង ប៊ីស្សព* (ឆ្នាំ 2010),ជំពូក 5, «ការបម្រើខាងសុខុមាលភាពសាសនាចក្រ» *ក្បួនខ្នាតភាគ 2 ៖ ការគ្រប់គ្រងសាសនាចក្រ* ( ឆ្នាំ 2010), ជំពូក 6, « គោលការណ៍សុខុមាលភាព និង ថ្នាក់ដឹកនាំ » *ការជួយឧបត្ថម្ភតាមរបៀបរបស់ព្រះអម្ចាស់ ៖ សេចក្ដីសង្ខេបអំពីការណែនាំដល់អ្នកដឹកនាំស្ដីអំពីសុខុមាលភាព* (កូនសៀវភៅ ឆ្នាំ 2009) ។

14. សៀវភៅរបស់អែលឌើរ ហ្គ្លិន អិល រ៉ុត *Pure Religion: The Story of Church Welfare since 1930* ( មាននៅកន្លែងចែកចាយរបស់សាសនាចក្រ) គឺជាកន្លែងដ៏ល្អ ដើម្បីសិក្សាគោលលទ្ធិ និង ប្រវត្តិសាស្ត្រ នៃកម្មវិធីសុខុមាលភាពសាសនាចក្រ ។

15. អេសាយ 58:10--11, សូមមើលខ 7--9 ផងដែរ ។